សម្រាប់ខ្សែរឿង ដំណើរឆ្ពោះទៅទិសខាងលិច នៃព្រះគ្រូថាំងចេង វគ្គបិសាចឆ្អឹងស គឺជាវិញ្ញាសាសាកល្បងមួយក្នុងចំណោមឧបសគ្គចំនួន៨១លើក ដែលព្រះសង្ឃ Xuanzang នៃរាជវង្សថាង និងសិស្សៗទាំងបីត្រូវប្រឈមមុខមុននឹងមកដល់ទឹកដីនៃការ«ត្រាស់ដឹង»។

រាជនគរនិងទឹកដីដ៏មានពន្លឺនៅភាគខាងលិច ជំនាន់នោះមិនមែនជាប្រទេសឥណ្ឌាទេ ជាកំណាកំណើតនៃពន្លឺ ស្មារតីនិងបណ្តុំអ្នកបួស ដែលកាលពីជាងមួយពាន់ឆ្នាំមុន គ្មានប្រទេសណាដែលហៅថាឈ្មោះថាឥណ្ឌានៅឡើយ។ ភូមិភាគនោះ មានកុលសម្ព័ន្ធតូចៗច្រើនរាប់រយជនជាតិ ស្នាក់នៅតាមរបៀបរៀងខ្លួនៗនាភាគខាងលិចនៃប្រទេសចិន រួមទាំងរដ្ឋកំណើតរបស់ព្រះពុទ្ធសក្យមុនី ដែលត្រូវបានគេស្គាល់ថា ជាប្រទេសនេប៉ាល់សព្វថ្ងៃនេះផង។

ដំណើររឿងបិសាចឆ្អឹងស បានកកើតឡើងយ៉ាងដូច្នេះថា កាលដើមបុរាណយូរលង់មកហើយ មានគ្រួសារគហបតីមួយត្រកូល«លី» ជាគ្រួសារល្បីឈ្មោះ មានដីស្រែច្រើន មានទាសករ និងមានអំណាចពន់ពេក។

ភរិយារបស់កូនប្រុសច្បងគ្រួសារនេះ មានឈ្មោះក្នុងការនិទានថា «អ្នកស្រីលី» ដែលជាជនដ៏អភ័ព្វអកុសលត្រូវបានអ្នកភូមិគ្រឹះចោទថា ជាស្ត្រីវាសនាចង្រៃ មិនមានកូនតពូជនិងថែមមិនស្មោះត្រង់និងប្តី ។

អ្នកស្រីលី ជានារីដ៏មានរូបសម្រស់ដែលត្រូវបានប្តីស្រលាញ់ថ្នាក់ថ្នម ប៉ុន្តែការទទួលបាននេះ គ្មានអ្វីក្រៅតែពីនាំមកនូវក្តីច្រណែនឫស្យាបង្កឡើងជាបញ្ហាដល់នាងមិនលោះថ្ងៃនិងកាន់តែធ្ងន់ឡើងៗ។ នាងមិនដែលធ្វើអ្វីត្រូវនៅក្នុងខ្សែភ្នែកម្តាយក្មេកឡើយ។

លី ធ្លាប់មានកូនម្តងដែរ តែត្រូវម្តាយក្មេកនិងបងៗថ្លៃបង្ខំឱ្យធ្វើការជាទម្ងន់ បង្អត់អាហារមិនឱ្យបន្ទប់កក់ក្តៅ ចាក់សោឱ្យគេងនៅគំនរចំបើងផ្ទះបាយ ពេលប្តីនាងមិននៅ ឧស្សាហ៍ទៅធ្វើជំនួញនៅទីក្រុងឆ្ងាយៗយូរថ្ងៃ។

ថ្ងៃមួយ ជាមួយការហត់នឿយ ជំងឺ និងស្រេកឃ្លានពន់ពេក នាងបានចូលទៅទោមនស្សនៅមុខព្រះម៉ែងវិហារមួយថា...ខ្ញុំឈប់ជឿអ្នកទៀតហើយ អ្នកឱ្យខ្ញុំធ្វើល្អ ប៉ុន្តែមនុស្សគ្រប់គ្នាមិនធ្វើល្អជាមួយខ្ញុំវិញសោះ ខ្ញុំឈប់បូជាអ្នកទៀតហើយ!។

ដោយទុក្ខរីងរៃនិងការធ្វើពលកម្មធ្ងន់ ក្រោយមកទារកប្រសូតមកស្លាប់ព្រោះកើតមិនគ្រប់ខែ

ដូច្នេះក្នុងវ័យ១៨ឆ្នាំអ្នកស្រីលីដ៏មានរូបសម្រស់ត្រូវបានគេសម្រេចយកទៅបំបរបង់ចោលឱ្យស្លាប់ម្នាក់ឯងលើកំពូលភ្នំដ៏ត្រជាក់ដាច់សង្វែងមួយតាមទំនៀមទម្លាប់ស្រុកភូមិកុំឱ្យចង្រៃដល់គ្រួសារ។

មុនពេលស្លាប់ នាងបានស្បថស្បែថាសូមកើតជាបិសាចមានអំណាចកាចសាហាវនិងគ្មានស្នេហា ថែមទាំងមិនមានចិត្តទន់ជ្រាយអ្វីជាមួយមនុស្សលោកដែលនាងស្អប់នឹងចងគំនុំ។

អ្នកស្រីលីត្រូវបានសត្វត្មាតចោះសព្វសាច់សល់តែឆ្អឹង ដែលរាប់ពាន់ឆ្នាំក្រោយមក ឆ្អឹងបានក្លាយជាព្រលឹងបិសាចដែលសំងំរៀនចេះនូវមន្តអាគមខ្មៅដ៏ជ្រៅជ្រះរហូតអាចមានលទ្ធភាពតំណែងខ្លួនគ្រប់ប្រភេទបាន។

ក្រោយមកបិសាចនេះតែងចាប់មនុស្សនៅភូមិក្បែរៗ មកបឺតជញ្ជក់ឈាមដើម្បីពង្រឹងថាមពលខ្លួនជាបន្តបន្ទាប់។ សូម្បីអ្នកស្លាប់ហើយ ក៏នាងប្រើមន្តឱ្យក្លាយជាបិសាចសាហាវ តាមហែហមបម្រើខ្លួន បន្តធ្វើអំពើឆក់ប្លន់ជីវិតមនុស្សជាហូរហែ នឹងកសាងបាននូវអាណាចក្ររបស់ខ្លួននាទីរហោដ្ឋាននោះ នឹងត្រូវបានមនុស្សម្នាខ្លបខ្លាចឱ្យឈ្មោះថា បិសាចឆ្អឹងស។

ជនជាតិចិនបានហៅនាងថា Baigujing 白骨精 ហើយ ឈ្មោះនេះត្រូវបានបកប្រែជាភាសាអង់គ្លេសថា White Bone Spirit នៅក្នុងការបកប្រែរបស់ William John Francis Jenner។ Baigujing ត្រូវបានគេពណ៌នាថា គឺជាបិសាចដែលផ្លាស់ប្តូររូបរាងបានច្រើនប្រភេទចំណែកទម្រង់ពិតរបស់នាង គឺជាគ្រោងឆ្អឹង។

ដូចគ្នានឹងបិសាចដទៃទៀតដែរនៅសម័យកាលនោះ បិសាចឆ្អឹងស ស្រេកឃ្លាននិងចង់ស៊ីសាច់របស់ព្រះគ្រូថាំងចេង Tang Sanzang ព្រោះវិញ្ញាណព្រលឹងទាំងអស់ដឹងថា សាច់នៃជនបរិសុទ្ធនេះនឹងនាំមកនូវជីវិតអមតៈ។

ថ្ងៃមួយដែលគ្រូនិងសិស្សទាំងបួនរូបបានឡើងឆ្លងកាត់ជម្រាលភ្នំខ្ពស់ដែលអ្នកស្រីលីបានត្រូវគេបោះបង់ឱ្យស្លាប់កាលពីរាប់ពាន់ឆ្នាំ ដំណឹងនេះបានកក្រើករំពើកដល់វិមានឆ្អឹងស។

មេឃរងាណាស់ថែមទាំងបានឆ្លងកាត់ការធ្វើដំណើរដ៏លំបាកលំបិនផង ព្រះសង្ឃថាំងមានអាការៈឃ្លានអាហារណាស់។ ស៊ុន អ៊ូខុងបានលោតចុះឡើង បំណងរំពៃរកមើលអាហារព្រៃ តែគេធុំក្លិនបិសាចនិងមានអារម្មណ៍ស្មានដឹងពីភាពមិនប្រក្រតីនៃតំបន់នេះ ដោយសារជំនាញពិសេសរបស់គេ។

មុនពេលចាកចេញ គេបានគូសរង្វង់ ហាមសិស្សប្អូននិងលោកគ្រូមិនឱ្យចាកចេញពីសីមាសិល្ប៍នេះជាដាច់ខាត មិនថាមានហេតុភេទបែបណាក្តី។

ចប់កិច្ចការពារគ្រូគេរួចហើយ បានហោះទៅពិនិត្យពីលើពពក ហើយបានរកឃើញចំការផ្លែប៉ៃសមួយទំព្រអូបនៅមិនឆ្ងាយពីទីនោះ ដូច្នេះហើយអ៊ូខុងបានសម្រេចចិត្តថានឹងទៅយ៉ាងរហ័សរើសផ្លែឈើខ្លះសម្រាប់អាហារថ្ងៃត្រង់។

តាមពិតក្រុមរបស់បិសាចឆ្អឹងស បានឃ្លាំមើលក្រុមគ្រូនិងសិស្សជាយូរមកណាស់ហើយ។ ដោយឃើញសត្វស្វាមហាទេពចាកចេញ បានឱ្យដំណឹងភ្លាមហើយឆ្អឹងសបានមានវត្តមានយ៉ាងលឿនមកក្នុងបំណងចូលទៅជិតផ្តាច់ជីវិតនិងឆីព្រះសង្ឃ ប៉ុន្តែនាងត្រូវខ្វាយថយក្រោយយ៉ាងឈឺចាប់ ដោយសារបុកទង្គិចនឹងជញ្ជាំងសីមាភ្លើងដែលមើលមិនឃើញ។

មិនយូរប៉ុន្មានបិសាចកំណាចមើលយល់ថាមានសីមាសិល្ប៍ដ៏មានឫទ្ធិនៅលើស្មៅ
។ បិសាចបានតំណែងខ្លួនមកជានារីវ័យក្មេងស្រស់ស្អាតម្នាក់ ផុសឡើងនៅលើផ្លូវភ្នំ ពីចម្ងាយដៃម្ខាងកាន់ឆ្នាំងសេរ៉ាមិចពណ៌ខៀវ និងដៃម្ខាងកាន់ដបប៉សឺឡែនពណ៌បៃតង។

ជូ ប៉ាជេ ជាទេវៈជ្រូកដែលត្រូវព្រះម៉ែគួនអ៊ីម ដាក់ភារៈឱ្យតាមបម្រើព្រះសង្ឃថាំងទៅចម្លងធម៌ក្នុងនាមជាសិស្សទីពីរនោះ ជាសភាវៈដែលមានកាមកិលេសជាប់ខ្លួន។ គេចាប់ផ្តើមមានការរំភើបចិត្តជាខ្លាំង ពេលបានឃើញនាង ហើយបានលោតចេញក្រៅជញ្ជាំងសីមា ដោយមិនបានពិគ្រោះអ្វីជាមួយលោកគ្រូនិងសិស្សប្អូនម្នាក់ទៀតឡើយ។

"ជម្រាបសួរ នារីវ័យក្មេង" គាត់បានស្វាគមន៍នាងដោយការដៀមដាមចែចង់យ៉ាងជ្រាលជ្រៅ "តើកាន់អ្វីធ្ងន់ម្ល៉េះខ្ញុំគួរអាចជួយបាន?"

បិសាចឆ្អឹងសតបស្រួយស្រែសថា៖

"មានបាយចំហុយនៅក្នុងឆ្នាំងខៀវ ហើយទឹកតៅហ៊ូក្នុងដបបៃតង" នារីវ័យក្មេងឆ្លើយដោយរីករាយ។

"វាជាអាហារថ្ងៃត្រង់ដែលខ្ញុំធ្វើសម្រាប់ប្តីខ្ញុំ និងកម្មកររបស់យើងដែលធ្វើការនៅវាល។ ទោះជាយ៉ាងណា បើអ្នកនិងគ្រូអ្នកឃ្លាន ខ្ញុំរីករាយនឹងផ្តល់ជូនអ្នករាល់គ្នា»។

ជ្រូកមិនដែលសប្បាយចិត្តអ្វីជាងនេះទៀតទេ បានជូននាងមកជួបនឹងគ្រូភ្លាមដែរ ប៉ុន្តែព្រះសង្ឃបានបដិសេធមិនទទួលទានអាហារថ្ងៃត្រង់ ដែលជាចំណែកសម្រាប់ប្តីនាងទេ។

ការណ៍នេះធ្វើឱ្យកិច្ចសន្ទនាត្រូវបន្លាយពេល ឯនៅពេលនោះ ស្វាអ៊ូខុងក៏បានត្រឡប់មកវិញល្មមដោយមានផ្លែប៉េសមួយក្តាប់តូច។ មហាទេពគ្រាន់តែមកដល់ក៏ដឹងអំពីសមាសភាពបិសាចនៃនារីតំណែងខ្លួនម្នាក់នេះបាត់ទៅហើយ។

អ៊ូខុងប្រញាប់ប្រញាល់ដាក់ផ្លែប៉េសចុះ ទាញកូនដំបងមាសចេញពីត្រចៀក ហើយវាយយ៉ាងខ្លាំងទៅលើនារីវ័យក្មេង។ នាងបានដួលស្លាប់នៅនឹងកន្លែងចំណែកវិញ្ញាណជាបិសាចឆ្អឹងសបានហើរទៅគេចបាត់រង់ចាំឱកាសថ្មីទៀត។

"ហេតុអ្វីឯងត្រូវសម្លាប់ជីវិត?!" ព្រះសង្ឃក្រោធខឹង។

មហាទេពស៊ុនតម្រង់ភ្នែកព្រះសង្ឃ រួចពិនិត្យទៅអាហារដែលរាយប៉ាយនៅលើដី។

«គ្មានអង្ករទេ មានតែដង្កូវនាង និងគ្មានតៅហ៊ូស្ងួតទេ គឺសត្វល្អិតទាំងអស់! ឃើញទេ ប៉ាជេឯងត្រូវបានគេបោកប្រាស់នៅតែបន្តិចទៀត បិសាចនឹងឆីឯង ហើយធ្វើគតលោកគ្រូបាន»

ព្រះសង្ឃទើបតែនឹងជេរសម្តីកូនសិស្សច្បង ស្រាប់តែលេចចេញស្ត្រីចំណាស់ម្នាក់ទៀតរត់រលះរលាំងមកដោយខឹងនិងយំ សំដៅមករកពួកគេ។

«លោកគ្រូ» មីងនោះស្រែកដាក់ព្រះសង្ឃថាំង «ខ្ញុំចង់ឲ្យអ្នកដាក់ទោសសត្វស្វាដ៏អាក្រក់នេះដែលបានសម្លាប់កូនស្រីរបស់ខ្ញុំ»។

ជ្រូកជូប៉ាជេ សួរឡើងដោយឆ្ងល់ថា «ខ្ញុំសូមទោសលោកស្រី ធ្វើម៉េចដឹងថាគាត់សម្លាប់កូនស្រី? ក្រែងទើបតែមកដល់ទេតើ?»

ស្ត្រីចំណាស់យំយ៉ាងជូរចត់រៀបរាប់ថា

"ខ្ញុំតាមដាននាងព្រោះសង្ស័យនាងមានលាក់កំបាំងប្រុសសាហាយ! គ្រប់យ៉ាងដែលសិស្សច្បងអ្នកបានធ្វើ កុំគិតថាអ្នកអាចបិទបាំងឧក្រិដ្ឋកម្មនេះបាន"។

មហាទេព បានស្រែកសារភាពថា "បិទបាំងស្អីទៅ បិសាចនេះខ្ញុំជាអ្នកវាយសម្លាប់! ឈប់យំសោកទៅ វាមិនមែនជាកូនស្រីរបស់អ្នកទៀតទេ តែជាខ្លួននាងដែលត្រូវបិសាចបីតឃោមសម្លាប់ហើយចូលមករស់នៅប្រុងប្រើរាងកាយនាងមកប្រហារលោកគ្រូខ្ញុំ! វិញ្ញាណអាក្រក់បានរត់គេចខ្លួន ហើយឥឡូវនេះវាបានចូលបន្លំក្នុងខ្លួនមនុស្សស្ត្រីចំណាស់ម្នាក់វិញ»។

ស្ត្រីចំណាស់បានភិតភ័យព្រោះអ៊ូខុងហាក់បានដឹងពីសមាសភាពរបស់ខ្លួន តែនៅពេលក្រឡេកឃើញព្រះគ្រូថាំងដែលនៅមានទឹកមុខអៀនខ្មាសព្រោះការវាយសម្លាប់របស់សិស្សខ្លួន ស្ត្រីនេះមិនបោះបង់ចោលល្បិចកលបន្តធ្វើជាឆោឡាឡើងថា ៖

"ខ្ញុំនឹងកត់ត្រារឿងនេះទៅឲ្យអ្នករាល់គ្នានៅក្នុងភូមិបានដឹងថាគ្រូនិងសិស្សជាបិសាច និងជាឃាតកៈ។ ក្រុមគ្រូនិងសិស្សនេះនឹងរស់នៅទៅមុខដោយខ្មាសខ្លួនឯងជារៀងរហូត"។

ស៊ុនអ៊ូខុងលើកកូនដំបងមាសវាយផ្ទង់ទៅលើស្ត្រីចំណាស់យ៉ាងខ្លាំងបណ្ដាលឱ្យគាត់ត្រូវដួលហើយស្លាប់។

«១ទៀតហើយ?» ព្រះសង្ឃមានការខឹងសម្បាចាកចោលសីមាសិល៍្បមកក្រៅវង្វង់សូត្រធម៌ឱ្យសពទាំងទ្វេ។ អ៊ូខុងមិនទាន់បានបកស្រាយយ៉ាងណានៅឡើយផងរំពេចនោះ នៅចុងផ្លូវលេចចេញបុរសចំណាស់ម្នាក់យំយែករត់មកដល់កន្លែងកើតហេតុ។ លោកតាបានយំ ហើយចោទប្រកាន់ឡើងថា៖

"គ្រូនិងសិស្សនេះបានសម្លាប់ កូនស្រីខ្ញុំ និងប្រពន្ធខ្ញុំ ពេលនេះខ្ញុំចង់ឲ្យអ្នកសងជីវិត"

ថាចប់គាត់លូកដៃមកទាញយករាងកាយព្រះគ្រូ តែស្វាអ៊ូខុងដឹងជាស្រេចពីគម្រោងរបស់បិសាចឆ្អឹងសនៅក្នុងរាងកាយបុរសចំណាស់បានជា មហាទេពស្រែកគ្រហឹមហើយវាយក្បាលជននោះសាជាថ្មីដោយដំបូងរហូតបណ្ដាលឱ្យ បុរសចំណាស់បានដួលស្លាប់។

សពទាំងបីបានធ្វើឱ្យព្រះសង្ឃស្រឡាំងកាំង ព្រោះសណ្ឋានជាសពកសិករពិតៗ មិនមានត្រង់ណាបង្ហាញថាជាបិសាចសោះ។ ព្រះគ្រូថាំងចេងមានសង្ឃដីកាថា៖

«អ៊ូខុង អ្នកមានចរិតឆេវឆាវដូចអ្នកចម្បាំងចចក ដែលផ្ទុយនឹងគោលការណ៍របស់ខ្ញុំក្នុងការទៅចម្លងធម៌! ឥឡូវខ្ញុំសម្រេចថា បណ្ដេញអ្នកចេញហើយ»។

មហាទេពពិតជាមានមនោសញ្ចេតនានិងបារម្ភក្រៃណាលើព្រះសង្ឃថាំង ទើបអ៊ូខុងសួរវិញថា៖

«បើលោកគ្រូបណ្ដេញខ្ញុំ តើនរណាមកការពារលោកគ្រូពីបិសាចទៅ? សូមលោកគ្រូមេត្តាផ្ដល់ឱកាសលើកទីពីរឲ្យសិស្សផង!"

ព្រះសង្ឃមិនបានថមថយចិត្តដែលអាក់អន់សោះឡើយ ព្រះគ្រូបញ្ជាក់ឡើងថា ៖

"ចាកចេញចុះ! ខ្ញុំមិនត្រូវការឃើញកិច្ចការពាររបស់អ្នក ដែលសម្លាប់មនុស្សមានជីវិតទុកថា ជាល្បែងបែបនេះទៀតនោះទេ"។

ដោយយំយែកតូចចិត្តដែលខំការពារគ្រូបែរជាទទួលទោស អ៊ូខុងបានចាកចេញភ្លាម។ មិនយូរប៉ុន្មាន បិសាចឆ្អឹងសបានបង្ហាញខ្លួនក្នុងទម្រង់ជាបិសាចនិងសើចក្អាកក្អាយថា៖

«អ្នកបួសដ៏មានចិត្តសប្បុរសអើយ ឥឡូវនេះហើយអ្នកនឹងក្លាយជាចំណីនៃយើង!»

ដោយជ្រូកប៉ាជេនិងអារក្សទឹកមានយុទ្ធសិល្ប៍ខ្សោយពេក បើធៀបនឹងបិសាចពាន់ឆ្នាំមួយនេះ វាក៏ចាប់បានព្រះសង្ឃនិងសិស្សទាំងពីរយកទៅល្អាងបានសម្រេចគ្រានោះ។

ប៉ាជេទាំងភ័យខ្លាចនិងងឿងឆ្ងល់ព្រោះត្រូវបានជាប់ក្នុងទ្រុងរង់ចាំការសម្លាប់បានស្រែកសួរថា៖

«តើនាងជាបិសាចអ្វី ម៉េចក៏នៅមានជីវិតបានបន្ទាប់ពីត្រូវគេវាយសម្លាប់ដោយដំបងមាសសិស្សច្បងយើងដល់ទៅបីដង?»

បិសាចឆ្អឹងសបានសើចចំអកថា៖

"ប្រហែលជាយើងមានវាសនាត្រូវរស់បន្តដើម្បីទទួលបានសាច់គ្រូឯងមកបន្តជីវិតអមតៈឱ្យខាងតែបាន!" នាងនិយាយនិងស្រែកឡើងដោយភាពរីករាយ។

ជ្រូកប៉ាជេមានការភ្ញាក់ផ្អើលខ្លាំង តែខំកែស្ថានការណ៍ថា៖

«ឯងឆ្កួតយើងទៅ គ្រូយើងគ្មានសាច់ទេ មិនឆ្ងាញ់ឡើយ!»

បិសាចឆ្អឹងសគ្រវីក្បាល មិនស្តាប់តាមការណែនាំរបស់ប៉ាជេសោះនាងឆ្លើយបញ្ឈឺឡើងថា៖

«ឯងឆ្កួតច្រើនពេក ហើយមានគំនិតរាក់ហួស ក៏ស្មានថា គ្រប់គ្នាគេល្ងង់ដូចឯង!»

«អត់ទេ! សូមកុំស៊ីគាត់!»

ប៉ាជេចាប់ផ្តើមស្រែកយំអង្វរឡើងដោយទុក្ខព្រួយថែមទាំងបកស្រាយទៀតថា

"មិនមានភស្តុតាងដែលសាច់គ្រូយើងអាចធ្វើឱ្យមានជីវិតអមតៈទេ ទុកគាត់ទៅចម្លងធម៌ប្រោសពួកឯងទៅ" ។

បិសាចសើចក្អាកក្អាយថា៖

«យើងមិនត្រូវការការប្រោសទេ យើងឈឺចាប់គ្រប់គ្រាន់ហើយ ការធ្វើជាអ្នកឈឺចាប់មិនមែនជាតួនាទីយើងទៀតទេយើងត្រូវការឃើញគេឈឺចាប់!»

ប៉ាជេធ្វើពុតជាសន្លប់និងខ្សោះខ្សោយជិតស្លាប់។ បិសាចក៏បញ្ជាឱ្យកូនចៅយកទៅចម្អិន។ គ្រានោះជាឱកាសជ្រូកប៉ាជេបានធ្វើឱ្យរបូតចំណងនឹងរត់ចេញយ៉ាងលឿន។

ប៉ាជេបានហោះយ៉ាងហត់នឿយសំដៅទៅកាន់ល្អាងភ្នំគូលេន ជាទឹកដីនៃនគរស្វាហើយប្រកាសតាមរកសិស្សច្បងដែលជាមហាទេពស្មើមេឃយ៉ាងឧឡារិក។

ស្តេចស្វាស៊ុនអ៊ូខុងបានឱ្យទាហានស្វាបណ្តើរជ្រូកប៉ាជេចូលមកបង្គំខ្លួនដែលកំពុងសម្រាកនៅលើបល្ល័ង្ករាជ។

ដោយបានដំណឹងភ្លាម អ៊ូខុងបានយោងប្អូនឡើងហើយហោះទៅជាបន្ទាន់។

នៅពេលទៅដល់មាត់ទ្វារ អ៊ូខុងបានប្រើដំបងឈើងកាង វាយកំទេចអាណាចក្រឆ្អឹងសជាបំណែកៗ ធ្វើឱ្យប្រធានក្រុមបិសាចមួយរូបប្រញាប់ប្រញាល់រៀសចូលទៅកាន់ល្អាងស្តេចបិសាចរបស់ខ្លួន ដោយរាយការណ៍ពីវិបត្តិនៅច្រកទ្វារខាងមុខ។

ខណៈនេះបិសាចឆ្អឹងស កំពុងរីករាយនឹងស្រាដែលត្រៀមក្លែមជាមួយសាច់អមតៈ។

នាងកំពុងរង់ចាំការកម្តៅចានគោមសម្រាប់អាំងព្រះសង្ឃ។

"កុំប្រកាសអាសន្នអ្វីទាំងអស់" បិសាចឆ្អឹងសតបទាំងអារម្មណ៍ពាក់កណ្តាលស្រវឹង។

ភ្លាមៗនោះស៊ុន អ៊ូខុងបានសម្រុកចូលមកដល់ធ្វើឱ្យបិសាចឆ្អឹងស ត្រូវស្វាងឡើងខំរំពែរកច្រកនឹងបានរត់ប្រាសអាយុ។

នៅតាមផ្លូវដើម្បីគេចពីស្តេចស្វា វាបានឃើញសាកសពទាហានដ៏មហិមារបស់ខ្លួននៅគ្រប់រូងភ្នំ។ ឃើញថាគ្មានផ្លូវនឹងគេចចេញយករួចជីវិត ក៏បែរទៅនិយាយទៅស្វាថា៖

"ហេតុអ្វីបានជាយើងមិនអាចនិយាយបាន? ខ្ញុំតែងតែត្រៀមនឹងនិយាយល្អៗជាមួយអ្នក ប៉ុន្តែអ្នកមិនដែលផ្តល់ឱកាសឱ្យខ្ញុំទេ"។

"លាមក! សត្វចម្លែកដែលស៊ីសាច់មនុស្ស នឹងមានអ្វីល្អក្នុងការនិយាយគ្នាទៅ!" ជ្រូកប៉ាជេចំអក។

ស្វាទេពងក់ក្បាលយល់ស្របតាមជូប៉ាជេ ហើយកាន់សម្លៀកបំពាក់មាសយ៉ាងតឹងត្រៀមប្រយុទ្ធ។ បិសាចឆ្អឹងសបានប្រណម្យទៅកាន់ព្រះគ្រូថាំងចេងថា៖

"អ្នកមិនស្គាល់ខ្ញុំទេ! មុនពេលខ្ញុំស្លាប់និងរលួយទៅគ្រោងឆ្អឹង ខ្ញុំជាស្ត្រីអភ័ព្វ ជាមនុស្សធ្វើល្អម្នាក់ ស្មោះត្រង់ចំពោះគ្រួសារប្តី!»

"គ្រប់គ្រាន់ហើយនឹងល្បិចកុហករបស់ឯង!"

ស៊ុនអ៊ូខុងមានការធុញទ្រាន់ តែព្រះគ្រូចង់ស្តាប់នាងបន្ត។ ភ្លាមនោះនាងបានឱកាសល្អប្រុងថានឹងហក់ទៅប្រខាំលោកគ្រូយកជីវិតអមតៈសិន តែស៊ុនអ៊ូខុងដែលបានត្រៀមរួចរាល់បានវាយដំយ៉ាងដំណំទៅលើរូបនាងពីក្រោយរហូតដួលត្មោលក្លាយមកជាគំនរឆ្អឹងស។

ព្រះសង្ឃសូត្រធម៌ឡើងដោយក្តីដោយតក់ស្លុត។ បន្ទាប់មកព្រះគ្រូបានប្រកាសទទួលយកស្វាទេពជាសិស្សដូចដើម ដើម្បីចាប់ផ្តើមបន្តដំណើរទៅកាន់ដែនដីត្រាស់ដឹង។

នៅតាមផ្លូវ អារក្សទឹកបានសួរសិស្សច្បងថា៖

"ល្បងស៊ុន! មានរឿងមួយដែលខ្ញុំមិនយល់ច្បាស់នៅឡើយទេ! ហេតុអ្វីបានជាមនុស្សស្រី និងមនុស្សស្លាប់ទាំងនោះមិនបានកើតជាមនុស្ស ប៉ុន្តែក្លាយទៅជាបិសាចស៊ីសាច់មនុស្ស?"

ព្រះសង្ឃបានឆ្លើយជំនួសទាំងដកដង្ហើមធំថា ៖

"កាលនៅជាមនុស្ស គេស្អប់ជាតិសាសន៍របស់ខ្លួនហើយស្បថស្បែដោយគំនុំ"។